# តារាងស្តីពីព័ត៌មានរបស់គម្រោង

លេខPIP : 1217

(សម្រាប់បំពេញដោយក្រសួងផែនការ)

## ព័ត៌មានមូលដ្ឋានអំពីគម្រោង

ផ្នែក ក

*(ត្រូវបំពេញគ្រប់ចំណុចទាំងអស់)*

១. ឈ្មោះគម្រោង : គម្រោងជំរុញឧស្សាហកម្មពូជដំណាំនៅកម្ពុជា

២. កាលបរិច្ឆេទគម្រោង

កាលបរិច្ឆេទចាប់ផ្តើមគម្រោង 01/01/24

កាលបរិច្ឆេទបញ្ចប់គម្រោង 31/12/26

៣. ចំណាយគម្រោងសរុប $960,000

៤. ស្ថាប័នទទួលខុសត្រូវ ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ

RESPONSIBLE UNIT

អង្គភាពទទួលខុសត្រូវ អគ្គនាយកដ្ឋានកសិកម្ម

៥. ស្ថានភាពគម្រោង គម្រោងដែលបានលុបចោល

ព័ត៌មានលម្អិតអំពីគម្រោង

៦. ប្រភេទគម្រោង ៖ គម្រោងជំនួយបច្ចេកទេស

៧. ប្រភពហិរញ្ញប្បទាន៖ ស្វែងរកម្ចាស់ជំនួយ

៨. មុំនៃគោលនយោបាយក្នុងយុទ្ធសាស្ត្របញ្ចកោណ ជំណាក់កាលទី១ ដែលគម្រោងស្ថិតនៅ

មុំទី២- ការលើកស្ទួយសហគ្រាសធុនមីក្រូ តូច និងមធ្យម ធុរកិច្ចថ្មី សហគ្រិនភាព និងការអភិវឌ្ឍសេដ្ឋកិច្ចក្រៅប្រព័ន្ធ

៩. ការចូលរួមចំណែករបស់គម្រោងក្នុងការសម្រេចបានគោលនយោបាយអាទិភាពខាងលើ

-បង្កើនសមត្ថភាពដល់មន្ត្រីមានសមត្ថកិច្ច និងកសិករស្តីពីបច្ចេកទេសគ្រប់គ្រងគុណភាពពូជដំណាំស្របតាមស្តង់ដាពូជ ដំណាំជាតិ

-ធានាថាកសិករ និងអ្នកដាំដុះផ្សេងទៀតទទួលបានពូជដំណាំដែលមានគុណភាពខ្ពស់ និងប្រភេទពូជល្អៗដែលអាចសម្រេចបានពេញលេញនូវសក្តានុពលនៃផលិតភាពកសិកម្ម និងការនាំចេញផលិតផល

-កសិករទទួលបានបណ្តាញផ្គត់ផ្គង់ពូជដំណាំប្រកបដោយភាពទុកចិត្ត និងមានប្រសិទ្ធភាពសេដ្ឋកិច្ចខ្ពស់

-ពង្រឹងការអនុវត្តច្បាប់ស្តីពីការគ្រប់គ្រងពូជដំណាំ និងសិទ្ធិអ្នកបង្កាត់ពូជដំណាំ និងលិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធនានា។

១០. ការគាំទ្រដល់គោលនយោបាយអភិវឌ្ឍន៍ វិស័យឧស្សាហកម្មកម្ពុជា

តើគម្រោងនេះគាំទ្រដល់ការអនុវត្តគោលនយោបាយអភិវឌ្ឍន៍វិស័យឧស្សាហកម្មកម្ពុជាដែរឬទេ? មិនគាំទ្រ

១១. វិស័យ (សូមប្រើវិស័យ អនុវិស័យ ដែលមានចែងក្នុងផ.យ.អ.ជ. )

ដំណាំតាមរដូវ: ស្រូវ និងផ្សេងៗ

១២. ទីតាំងអនុវត្តគម្រោង (ពិពណ៌នាពីទីតាំងដែលត្រូវអនុវត្តគម្រោង)

បន្ទាយមានជ័យ, កំពង់ចាម, សៀមរាប, ព្រៃវែង, កំពង់ធំ, ត្បូងឃ្មុំ , កណ្តាល, តាកែវ, បាត់ដំបង, កំពង់ឆ្នាំង, ពោធិ៍សាត់,

១៣. គោលបំណងរបស់គម្រោង (ពិពណ៌នាគោលបំណងចម្បងៗរបស់គម្រោង)

-ពង្រឹងសមត្ថភាព និងជំនាញដល់មន្ត្រីមានសមត្ថកិច្ច (ថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ) និងស្ថាប័នពាក់ព័ន្ធលើយន្តការគ្រប់គ្រងវិស័យឧស្សាហកម្មពូជដំណាំនៅកម្ពុជា

-រៀបចំនីតិវិធីត្រួតពិនិត្យគុណភាពពូជដំណាំលើរាល់សកម្មភាពអភិវឌ្ឍន៍ និងអាជីវកម្មពូជដំណាំគ្រប់ប្រភេទដល់អ្នកពាក់ព័ន្ធនៅក្នុងវិស័យពូជដំណាំ

- បង្កើនការជឿជាក់ និងទំនុកចិត្តពីអ្នកពាក់ព័ន្ធនានាក្នុងវិស័យពូជដំណាំលើអត្ថប្រយោជន៍នៃការប្រើប្រាស់ពូជដំណាំដែលមានគុណភាពខ្ពស់ និងប្រភេទពូជល្អ តាមរយៈយន្តការផ្សព្វផ្សាយ បណ្តុះបណ្តាល ស្រែ ឬចំការបង្ហាញ និងទិវាស្រែ ឬចំការ

-ពង្រឹងកិច្ចសហប្រតិបត្តិការ និងការផ្លាស់ប្តូរពត៌មានរវាងអ្នកពាក់ព័ន្ធក្នុងការអភិវឌ្ឍន៍ឧស្សាហកម្មពូជដំណាំ។

១៤. ការពិពណ៌នាអំពីគម្រោង (ពិពណ៌នាអំពីសមាសភាគទាំងអស់របស់គម្រោង)

គម្រោងនេះនឹងផ្តោតទៅលើសកម្មភាពការងារសំខាន់ៗមួយចំនួនដូចខាងលក្រោម៖

-ការពង្រឹងសមត្ថភាពមន្ត្រីថ្នាក់កណ្តាល និងក្រោមជាតិ ៖ ការបណ្តុះបណ្តាលមន្ត្រីនៃនាយកដ្ឋានពូជដំណាំ និងមន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទពីនីតិវិធីនៃការត្រួតពិនិត្យ គោលការណ៍ណែនាំនានា ការវាយតម្លៃគុណភាពពូជដំណាំតាមប្រព័ន្ធធានាគុណភាពពូជដំណាំ និងបណ្តុះបណ្តាបច្ចេកទេសស្តីពីការវាយតម្លៃគុណភាពប្រភេទពូជថ្មីនៃដំណាំដោយ គោលការណ៍ណែនាំ Distinguish Uniform and Stable (DUS) និង Value for Cultivation and Uses (VCU)

-ការផ្សព្វផ្សាយ និងពង្រឹងការអនុវត្តច្បាប់ ព្រមទាំងលិខិតបទដ្ឋានគតិយុត្តក្រោមច្បាប់៖ ជំរុញការផ្សព្វផ្សាយច្បាប់ និងលិខិតបទដ្ឋានគតិយុត្តក្រោមច្បាប់ស្តីពីការគ្រប់គ្រងពូជដំណាំ និងសិទ្ធិអ្នកបង្កាត់ពូជដំណាំ និងនីតិវិធីចុះបញ្ជីប្រភេទ ពូជដំណាំ និងបញ្ជាក់គុណភាពពូជដំណាំដល់អ្នកពាក់ព័ន្ធនានានៅក្នុងវិស័យពូជដំណាំ រួមមាន មន្ត្រី អាជីវករ កសិករ និងក្រុមហ៊ុននានា នៅតាមបណ្តារាជធានី ខេត្តឱ្យបានទូលំទូលាយបន្ថែមទៀត

-ការកសាងឯកសាបច្ចេកទេសពាក់ព័ន្ធនានា ៖ ១.កសាងឯកសារបច្ចេកទេសស្តីពីគោលការណ៍ណែនាំបច្ចេកទេស និងដំណើរការវាយតម្លៃគុណភាព និងការបញ្ចេញពូជថ្មីនៃដំណាំ ២.រៀបចំបញ្ជីពូជដំណាំជាតិ នីតិវិធីផ្តល់ជាវិញ្ញាបនបត្របញ្ជាក់គុណភាពពូជដំណាំ និងការវិភាគគុណភាពពូជដំណាំ ៣.រៀបចំសៀវភៅបច្ចេកទេសស្តីពីពិធីសារពិសោធន៍វាយតម្លៃសម្តែងកម្ម នៃពូជដំណាំនៅទីវាលដើម្បីធ្វើអាជីវកម្ម និងពិសោធន៍វាយតម្លៃ DUS និង VCU ៤.រៀបចំសៀវភៅស្តីពីការ ពិពណ៌នាចរិតលក្ខណៈនៃប្រភេទពូជដំណាំជាតិ

-ការបង្កើតទិន្នន័យពត៌មានគ្រឹះស្តីពីគ្រប់គ្រងពូជដំណាំ៖បង្កើតប្រព័ន្ធគ្រប់គ្រងទិន្នន័យគ្រឹះសម្រាប់ការចុះបញ្ជីប្រភេទពូជដំណាំ និងការបញ្ជាក់គុណភាពពូជដំណាំ ព្រមទាំងអាជីវកម្មពូជដំណាំ (ការនាំចេញ នាំចូល ការចែកចាយ និងសន្និធិពូជដំណាំ) និងពង្រឹងសតម្ថភាពដល់មន្ត្រីស្តីពីការគ្រប់គ្រងប្រព័ន្ធទិន្នន័យគ្រឹះ។

-ការផ្តល់បច្ចេកទេស និងរៀបចំស្រែ ចំការបង្ហាញពីការផលិតពូជប្រកបដោយគុណភាព ការកត់ត្រា ទុកដាក់ពូជ និងទីផ្សារពូជដល់សហគមន៍កសិករផលិតពូជ

១៥. យុត្តិកម្មលើគម្រោង (បង្ហាញពីហេតុផលថាហេតុអ្វីបានជាគម្រោងនេះត្រូវបានជ្រើសរើស)

បច្ចុប្បន្នវិស័យកសិកម្មនៃព្រះរាជាណាចក្រកម្ពុជា កំពុងស្ថិតនៅក្នុងស្ថានភាពអភិវឌ្ឍន៍មួយដែលកំពុងកែប្រែពីផលិតកម្មកសិកម្មគ្រួសារតាមបែបបិវុលកម្ម ពឹងផ្អែកសំខាន់លើធនធានធម្មជាតិដែលមានស្រាប់ និងការប្រើប្រាស់ធាតុចូលកសិកម្មតាមបែបប្រពៃណីឈាន ទៅរកដំណាក់កាលថ្មីផ្តោតទៅលើរូបភាពផលិកម្មកសិកម្មតាមបែបប្រពលវប្បកម្មដោយផ្អែកសំខាន់លើការអនុវត្តបច្ចេកវិទ្យាទំនើប នៅគ្រប់ដំណាក់កាលនៃខ្សែសង្វាក់ផលិតកម្មកសិកម្ម។ ក្នុងចំណោមធាតុចូលសំខាន់ៗ ពូជដំណាំគឺជាចំណុចចាប់ផ្តើមនៃខ្សែសង្វាក់ផលិតកម្មនិងជាធាតុចូលដ៏សំខាន់ដែលជួយជំរុញឱ្យកសិករ និងអ្នកដាំដុះផ្សេងទៀត ទទួលបានទិន្នផលកសិផលខ្ពស់ប្រកបដោយគុណភាព នៅក្នុងពេលប្រមូលផល។ លើសពីនេះទៅទៀត ផលិតកម្មនិងទីផ្សារពូជដំណាំ អាចផ្តល់ឱកាសក្នុងការពង្រីកមុខរបរខ្នាតតូចនៅតំបន់ ជនបទផងដែរ។ ការប្រើប្រាស់ពូជដំណាំមានគុណភាពល្អ គឺជាកត្តាសំខាន់បំផុតមួយសម្រាប់បង្កើនទិន្នផល ក្នុងផលិតកម្មកសិកម្ម ហើយអាចផ្តល់ប្រយោជន៍យ៉ាងច្រើនដល់កសិករ និងអ្នកដាំដុះផ្សេងទៀតទាំងកសិកម្មខ្នាតតូច និងខ្នាតធំ។

វិស័យពូជដំណាំនៅព្រះរាជាណាចក្រកម្ពុជា ស្ថិតនៅក្នុងដំណាក់កាលដំបូងនៃការអភិវឌ្ឍដែលកំពុងជួបប្រទះនូវបញ្ហាប្រឈមមួយចំនួនទាំងបរិមាណ និងគុណភាពសម្រាប់បម្រើការងារដាំដុះ។ បច្ចុប្បន្ននេះ ដោយសារកំណើននៃសេចក្តីត្រូវការពូជដំណាំដែលមានគុណភាពល្អ ការផ្គត់ផ្គង់ពូជដំណាំតាមរយៈទីផ្សារដោយវិស័យឯកជនជាសញ្ញា វិជ្ជមានមួយក្នុងការងារផលិតកម្មពូជដំណាំ និងទីផ្សារ។ ដើម្បីធានាឱ្យមានកិច្ចសហការល្អជាមួយកសិករ និងវិស័យឯកជនក្នុងការគ្រប់គ្រងពូជដំណាំឱ្យមានប្រសិទ្ធ ភាព និងគុណភាពល្អ យោងតាមអនុក្រឹត្យលេខ១៦៣ អនក្រ.បក ចុះថ្ងៃទី០៧ ខែវិច្ឆិកា ឆ្នាំ២០១៩ អគ្គនាយកដ្ឋានកសិកម្ម បានបង្កើតនាយកដ្ឋានពូជដំណាំ ដែលមានភារកិច្ចចំបងលើការគ្រប់គ្រងរាល់សកម្មភាពអាជីវកម្មពូជដំណាំ ការធ្វើវិញ្ញាបនកម្មបញ្ជាក់គុណ ភាពពូជដំណាំ ជាអង្គភាពទទួលបន្ទុកអនុវត្តច្បាប់និងជាអង្គភាពបង្គោលសម្រាប់សម្របសម្រួលរាល់សកម្មភាព និងព័ត៌មាននានា ទាក់ទងនឹងពូជដំណាំ។

១៦. ផលប្រយោជន៍របស់គម្រោង (រៀបរាប់ពីអ្នកដែលនឹងទទួលប្រយោជន៍ផ្ទាល់និងមិនផ្ទាល់ពីការអនុវត្តគម្រោង)

-អ្នកទទួលផលផ្ទាល់ពីគម្រោងមានដូចជា មន្ត្រីមានសមត្ថកិច្ចថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ ក្រុមកសិករផលិត/ សហគមន៍ កសិកម្ម កសិករ អ្នកស្រាវជ្រាវ ដៃគូរអភិវឌ្ឍន៍ និងវិស័យឯកជននានាពាក់ព័ន្ធនឹងវិស័យពូជដំណាំ។

-អ្នកទទួលផលដោយប្រយោល មានដូចជា ក្រុមសគ្រួសារកសិករ អ្នកបរិភោគ អ្នកនាំចេញ និងក្រុមហ៊ុនកែច្នៃផលិតផលកសិកម្ម។

១៧. ការសិក្សាសមិទ្ធិលទ្ធភាព

| | |
|---|---|
| តើគម្រោងនេះតម្រូវឲ្យមានការសិក្សាសមិទ្ធិលទ្ធភាពដែរ ឬទេ? | **គ្មាន** |
| ប្រសិនបើត្រូវការ តើការសិក្សាសមិទ្ធិលទ្ធភាព បានរៀបចំហើយឬនៅ? | **មិនទានចាប់ផ្តើម** |

១៨. ផលប៉ះពាល់ផ្នែកបរិស្ថាននិងសង្គម (ពិពណ៌សង្ខេបពីផលប៉ះពាល់របស់គម្រោងលើប្រជាជននិងបរិស្ថានជុំវិញ ប្រសិនបើមាន។ តើគម្រោងនេះនឹងជួយដល់ការកាត់បន្ថយភាពក្រីក្រដែរឬទេ?)

**គម្រោងនេះ នឹងពុំមានផលប៉ះពាល់ដល់បរិស្ថាន និងសង្គមទេ។**

១៩. ការប្រែប្រួល អាកាសធាតុ

ក. តើសកម្មភាព ឬធាតុចេញរបស់គម្រោងទាក់ ទងនឹងការប្រែប្រួលអាកាសធាតុ ឬទេ? **មាន**

ប្រសិនបើទាក់ទងនឹងការប្រែប្រួលអាកាស ធាតុ សូមជ្រើសរើស **ការបន្សាំ**

ខ. តើគម្រោងមានភាពទាក់ទងនឹងការប្រែប្រួលអាកាសធាតុកម្រិតណា?

សូមជ្រើសរើសវិស័យដែលទាក់ទងនឹងការប្រែប្រួលអាកាសធាតុរបស់គម្រោងនិងបំពេញការចូលរួមចំណែកនៃចំណាយដែលទាក់ទងនឹងការប្រែប្រួលអាកាសធាតុរបស់គម្រោងធៀបនឹងតម្លៃគម្រោងសរុប។

| វិស័យដែលទាក់ទងនឹងការប្រែប្រួលអាកាសធាតុ | ភាគរយ | ភាពទាក់ទងនឹងការប្រែប្រួលអាកាសធាតុ |
|---|---|---|
| ២០. ការកាត់បន្ថយហានិភ័យ និងគ្រោះមហន្តរាយ | 30 | **ទាក់ទងតិចតួច** |

| | | |
|---|---|---|
| តើសកម្មភាព ឬធាតុចេញរបស់គម្រោងទាក់ទងនឹងការកាត់បន្ថយហានិភ័យ និងគ្រោះមហន្តរាយដែរឬទេ ? | **មាន** |
| ប្រសិនបើ ទាក់ទងនឹងការកាត់បន្ថយហានិភ័យនិងគ្រោះមហន្តរាយ សូមជ្រើសរើស | **ការត្រៀម** |

**២១. ការវិភាគយេនឌ័រ** (តើគម្រោងនេះមានផលប៉ះពាល់ដល់តួនាទីរបស់បុរសនិងស្ត្រីក្នុងទីតាំងរបស់គម្រោងនេះដូចម្ដេច ? តើស្ត្រីនឹងត្រូវចូលរួមយ៉ាងសកម្មក្នុងការអនុវត្តគម្រោងនេះដែរឬទេ ? )

**គម្រោងនឹងផ្ដល់អាទិភាព និងលើកទឹកចិត្តឲ្យស្ត្រីចូលរួមគ្រប់សកម្មភាព។**

**២២. សមត្ថភាពអនុវត្តគម្រោង** (តើក្រសួងមានជំនាញនិងបទពិសោធន៍គ្រប់គ្រាន់សម្រាប់អនុវត្តគម្រោងដែរឬទេ ? )

**ជាគម្រោងប្រើប្រាស់យន្តការគ្រប់គ្រងរបស់រដ្ឋបាលថ្នាក់កណ្ដាល និងថ្នាក់ក្រោមជាតិ នៃរចនាសម្ព័ន្ធមានស្រាប់របស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ។ ក្នុងករណីខ្វះខាតអ្នកជំនាញ គម្រោងនឹងធ្វើលទ្ធកម្មរកអ្នកជំនាញពីក្រៅរដ្ឋាភិបាលដើម្បីផ្ដល់ជាយោបល់ និងលើកទិសដៅតម្រង់ទិសគម្រោងឱ្យទទួលបានជោគជ័យ និងប្រសិទ្ធភាពខ្ពស់។**

**២៣. ស្ថានភាពនៃការអនុវត្តគម្រោង** (ពិពណ៌នាសង្ខេបអំពីវឌ្ឍនភាពរបស់គម្រោងនិងបង្ហាញអំពីភាពប្រឈមនានា ដែល បណ្ដាលឲ្យមាន ការព្យាពេលក្នុងការអនុវត្តគម្រោង។)

**សំណើគម្រោង មិនទាន់បានអនុវត្តនៅឡើយ។**

**២៤. អាទិភាពរបស់គម្រោង** (បញ្ជាក់ពីការកំណត់អាទិភាពរបស់គម្រោងរបស់ក្រសួង ស្ថាប័ន)

2

**២៥. ការចូលរួមរបស់ដៃគូអភិវឌ្ឍ** (ផ្ដល់ព័ត៌មានអំពីដៃគូអភិវឌ្ឍសក្ដានុពល ដែលពាក់ព័ន្ធនឹងគម្រោងនេះ)

**មិនទាន់មាន**

## ផ្នែក ខ ចំណាយរបស់គម្រោងនិងប្រភពហិរញ្ញប្បទាន

*(គិតជាពាន់ដុល្លារអាមេរិក)*

| ចំណាយវិនិយោគ | 2022 | | 2023 | 2024 | 2025 | 2026 | សរុប | ថវិកា |
|---|---|---|---|---|---|---|---|---|
| | ថវិកា | ជាក់ស្តែង | ថវិកា | ប៉ាន់ស្មាន | ប៉ាន់ស្មាន | ប៉ាន់ស្មាន | 2024-2026 | ចរន្ត |
| ចំណាយប្រតិបត្តិ | 0.0 | 0.0 | 0.0 | 20.0 | 20.0 | 20.0 | 60.0 | 0.0 |
| | | | | | | | | |
| បៀវត្សរ៍ | 0.0 | 0.0 | 0.0 | 0.0 | 0.0 | 0.0 | 0.0 | 0.0 |
| សម្ភារៈនិងរដ្ឋបាល | 0.0 | 0.0 | 0.0 | 0.0 | 0.0 | 0.0 | 0.0 | 0.0 |

| | | | | | | | | |
|---|---|---|---|---|---|---|---|---|
| ផ្សេងៗ | 0.0 | 0.0 | 0.0 | 20.0 | 20.0 | 20.0 | 60.0 | 0.0 |
| | | | | | | | | |
| **ចំណាយមូលធន** | 0.0 | 0.0 | 0.0 | 370.0 | 290.0 | 240.0 | 900.0 | 0.0 |
| | | | | | | | | |
| ការសាងសង់ | 0.0 | 0.0 | 0.0 | 0.0 | 0.0 | 0.0 | 0.0 | 0.0 |
| សេវាទីប្រឹក្សា | 0.0 | 0.0 | 0.0 | 0.0 | 0.0 | 0.0 | 0.0 | 0.0 |
| ទព្វសម្ភារៈ | 0.0 | 0.0 | 0.0 | 0.0 | 0.0 | 0.0 | 0.0 | 0.0 |
| ការបណ្តុះបណ្តាល | 0.0 | 0.0 | 0.0 | 270.0 | 230.0 | 170.0 | 670.0 | 0.0 |
| ផ្សេងៗ | 0.0 | 0.0 | 0.0 | 100.0 | 60.0 | 70.0 | 230.0 | 0.0 |
| | | | | | | | | |
| **ចំណាយសរុប** | 0.0 | 0.0 | 0.0 | 390.0 | 310.0 | 260.0 | 960.0 | 0.0 |
| | | | | | | | | |

| ប្រភពហិរញ្ញប្បទាន | 2022 | | 2023 | 2024 | 2025 | 2026 | សរុប | |
|---|---|---|---|---|---|---|---|---|
| | ថវិកា | ជាក់ស្តែង | ថវិកា | ប៉ាន់ស្មាន | ប៉ាន់ស្មាន | ប៉ាន់ស្មាន | 2024-2026 | |
| | | | | | | | | |
| ចំណូលពីគម្រោង | 0.0 | 0.0 | 0.0 | 0.0 | 0.0 | 0.0 | 0.0 | |
| | | | | | | | | |
| ថវិកាជាតិ | 0.0 | 0.0 | 0.0 | 0.0 | 0.0 | 0.0 | 0.0 | |
| | | | | | | | | |
| សាច់ប្រាក់សុទ្ធ | 0.0 | 0.0 | 0.0 | 0.0 | 0.0 | 0.0 | 0.0 | |
| ធនធានផ្សេងៗ | 0.0 | 0.0 | 0.0 | 0.0 | 0.0 | 0.0 | 0.0 | |
| | | | | | | | | |
| ហិរញ្ញប្បទាន របស់ ដៃគូអភិវឌ្ឍ | | | | | | | | |
| | | | | | | | | |
| | | | | | | | | |
| សរុបហិរញ្ញប្បទាន ដែលបានសន្យាផ្តល់ | 0.0 | 0.0 | 0.0 | 0.0 | 0.0 | 0.0 | 0.0 | |
| | | | | | | | | |
| តម្រូវហិរញ្ញប្បទាន បំពេញបន្ថែម | 0.0 | 0.0 | 0.0 | 390.0 | 310.0 | 260.0 | 960.0 | |

**បានឃើញ និង ឯកភាព**

**រដ្ឋមន្ត្រី**

កាលបរិច្ឆេទ: